**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ ០០១/ស.ល.ម/២០១៥

**សូមគោរពជូន**

**ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ ព្រឹទ្ធសភា**

**នៃព្រះរាជាណាចក្រកម្ពុជា**

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង ពលទាហាន នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្ញុំនិងភរិយា ខ្ញុំមានក្តីរន្ធត់ចិត្តឥតឧបមាចំពោះមរណភាពរបស់ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជានិងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃច័ន្ទ ៧រោជ ខែជេស្ឋ ឆ្នាំមមែ សប្តស័ក ពុទ្ធសករាជ ២៥៥៩ ត្រូវនឹងថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥ វេលាម៉ោង ១៥ និង ៥៥នាទី ក្នុងជន្មាយុ ៨៣ឆ្នាំ ដោយរោគាពាធ។

ក្នុងឱកាសដ៏ក្តុលក្តួលនេះ ខ្ញុំសូមចូលរួមមរណទុក្ខយ៉ាងក្រៀមក្រំនិងដោយក្តីស្រណោះអាឡោះអាល័យសោកស្តាយយ៉ាងក្រៃលែងជាមួយថ្នាក់ដឹកនាំ សមាជិក សមាជិកានិងមន្ត្រីរាជការនៃព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសាររបស់ **សម្តេចប្រធាន** ចំពោះការបាត់បង់នូវអគ្គមគ្គុទ្ទេសក៏ដ៏ល្អឆ្នើមមួយរូប គឺសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានគណបក្សប្រជាជន ប្រធានព្រឹទ្ធសភា ដែលជាមេដឹកនាំដ៏ឧត្តុង្គឧត្តម និងជាមេគ្រួសារ ជាបិតា ជាជីតា ជីតាទួត នៃក្រុមគ្រួសាររបស់ **សម្តេចប្រធាន** ប្រកបដោយព្រហ្មវិហារធម៌ដ៏ថ្លៃថ្លាបំផុត។

សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** គឺជាវីរជននិងជាមេដឹកនាំដ៏ឆ្នើមមួយរូបប្រកបដោយគុណធម៌ដែលបានបូជាកម្លាំងកាយ-ចិត្ត ប្រាជ្ញានិងស្មារតី ចូលរួមដឹកនាំកម្លាំងតស៊ូរំដោះប្រទេសនិងប្រជាជនយើងឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការស្តារនិងអភិវឌ្ឍន៍ជាតិមាតុភូមិឲ្យមានការរីកចម្រើនលើគ្រប់វិស័យដូចបច្ចុប្បន្ននេះ។ ជាងនេះទៀត **សម្តេចប្រធាន** បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្សះផ្សាបង្រួបបង្រួមជាតិ កសាងសុខសន្តិភាពនិងស្ថិរភាពនយោបាយសម្រាប់ជាតិមាតុភូមិយើង ហើយក្នុងឋានៈជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** បានបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមប្រកបដោយស្មារតីស្នេហាជាតិខ្ពស់បំផុត ចូលរួមចំណែកក្នុងការបណ្តុះនិងពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្សនិងនីតិរដ្ឋនៅកម្ពុជា។

មរណភាពរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** គឺជាការបាត់បង់ដ៏ធំធេងរបស់ប្រជាជាតិយើង។ កងយោធពលខេមរភូមិន្ទ សូមចងចាំជានិច្ចនូវគុណូបការៈដ៏ប្រសើរថ្លៃថ្លា ពលិកម្មដ៏ឧត្តុង្គឧត្តមនិងទឹកចិត្តស្នេហាជាតិដ៏ស្មោះស្ម័គ្ររបស់ **សម្តេចប្រធាន** ចំពោះជាតិមាតុភូមិនិងប្រជាជនកម្ពុជាជាទីស្នេហានៃយើង។

ក្នុងឱកាសដ៏ក្រៀមក្រំនិងសោកសង្រេងនេះ យើងខ្ញុំទាំងអស់គ្នាសូមលំអោនកាយឧទ្ទិសបួងសួង សូមឲ្យវិញ្ញាណក្ខន្ធរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** បានចាប់បដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម អនុប្រធានទី១** នៃព្រឹទ្ធសភា ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍.ទៀ~បាញ់**